Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយភ្លាមៗ

# ថ្នាក់ដឹកនាំមេគង្គនឹងអំពាវនាវឲ្យមានដំណោះស្រាយថ្មីៗ ក្នុងកិច្ចប្រជុំកំពូលរបស់ MRC នាពេលខាងមុខនេះ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនានា

*ប្រមុខរដ្ឋាភិបាលមកពីប្រទេសសមាជិកទាំងបួនរបស់គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា “MRC”) រួមមាន កម្ពុជា ឡាវ ថៃ និងវៀតណាម និងគណៈប្រតិភូជាន់ខ្ពស់មកពីប្រទេសជាដៃគូសន្ទនារបស់ MRC ពោលគឺចិននិងមីយ៉ាន់ម៉ា នឹងបើកកិច្ចប្រជុំកំពូលមួយនាដើមខែមេសាខាងមុខនេះ ដើម្បីកំណត់ជោគវាសនារបស់អាងទន្លេមេគង្គ។*

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២៣** ÷ កិច្ចប្រជុំកំពូលលើកទី៤ និងសន្និសីទអន្តរជាតិរបស់ MRC នឹងប្រព្រឹត្តទៅដោយមានការចូលរួមដោយផ្ទាល់ចាប់ពីថ្ងៃទី ២ ដល់ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០២៣ នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ។ ព្រឹត្តិការណ៍កម្រិតនយោបាយ ខ្ពស់បំផុតរបស់ស្ថាប័ននេះ នឹងនាំឲ្យប្រទេសតាមដងទន្លេមេគង្គទាំង៦ ជួបពិភាក្សាពីការអភិវឌ្ឍថ្មីៗ កាលានុវតន៍ និងដំណោះស្រាយបែបនវានុវត្តន៍លើបញ្ហាប្រឈមនានា ដោយរាប់ចាប់ពីផលវិបាកនៃ ការអភិវឌ្ឍដែលពាក់ព័ន្ធនឹងទឹករហូតដល់ការប្រែប្រួលអាកាសធាតុ ដែលបាននិងកំពុងជះឥទ្ធិពលដល់ទន្លេមេគង្គដែលជាមធ្យោបាយផ្លូវទឹកធំជាងគេបំផុតនៅតំបន់អាស៊ីអាគ្នេយ៍។

បណ្ឌិត អានុល័ក ខិធិឃួន (Anoulak Kittikhoun) នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC ថ្លែងថា “ទន្លេមេគង្គកំពុងឆ្លងកាត់នូវការផ្លាស់ប្តូរយ៉ាងសម្បើម។ យើងត្រូវតែច្នៃប្រឌិតឥតឈប់ឈរទាំងនៅក្នុងផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីនាំឲ្យការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គកាន់តែមានទំនួលខុសត្រូវ និងប្រកបដោយចីរភាព”។

កិច្ចប្រជុំកំពូលលើកទី៤ នឹងនាំមុខដោយសន្និសីទអន្តរជាតិមួយ នៅថ្ងៃទី ២ និង ទី ៣ ខែមេសា ឆ្នាំ ២០២៣ ដែលនឹងពិភាក្សាជុំវិញប្រធានបទ “នវានុវត្តន៍និងកិច្ចសហប្រតិបត្តិការសម្រាប់សន្តិសុខទឹក និងទន្លេមេគង្គប្រកបដោយចីរភាព”។

សន្និសីទនេះត្រូវបានគេរំពឹងថានឹងមានការចូលរួមពីភាគីពាក់ព័ន្ធ ជំនាញការ និងអ្នកចាប់អារម្មណ៍ពីកិច្ចការទន្លេមេគង្គនៅទូទាំងពិភពលោកទាំងអស់ប្រមាណ ៤០០ នាក់ ដោយរាប់ចាប់ពីស្ថាប័នរដ្ឋាភិបាល អង្គការអន្តរជាតិ វិស័យឯកជន អ្នកស្រាវជ្រាវ និងសង្គមស៊ីវិល។ អ្នកចូលរួមទាំងអស់នឹងធ្វើការផ្លាស់ប្តូរទស្សនៈប្រកបដោយការបំផុតគំនិត ចំណេះដឹងដែលបានអនុវត្ត រួមទាំង បទពិសោធន៍ជាក់ស្តែងជុំវិញនវានុវត្តន៍ពាក់ព័ន្ធនឹងទឹក ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទន្លេមេគង្គ។ សាធារណៈជន ឬអង្គភាពនានាដែលចាប់អារម្មណ៍ត្រូវចុះឈ្មោះចូលរួមជាមុន។ អ្នកជំនាញការត្រូវបានស្វាគមន៍ឲ្យដាក់សំណើរធ្វើបទបង្ហាញនៅឯសន្និសីទនេះ។

ព្រឹត្តិការណ៍ជាសកលនេះ នឹងគ្របដណ្ដប់លើការឆ្លុះបញ្ចាំងពីការអភិវឌ្ឍ និងទស្សនាទាននានា ព្រមទាំងបញ្ហាក្នុងការគ្រប់គ្រងអាងទន្លេមេគង្គ។ សុន្ទរកថាសំខាន់ៗពីថ្នាក់ដឹកនាំតាមវិស័យផ្សេងៗ នឹងរំលេចពីនវានុវត្តន៍ឈានមុខគេ នៅក្នុងផ្នែកគោលនយោបាយ បច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការ ឆ្លងដែន។

បរិបទទាំងនេះ នឹងបង្កលក្ខណៈងាយស្រួលដល់ការពិភាក្សាជាក្រុម ជុំវិញបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការបែបច្នៃប្រឌិតផ្សេងៗ ដែលបាននិងកំពុងផ្លាស់ប្ដូរការគ្រប់គ្រងទឹកឆ្លងដែន និងរបៀបដែលហិរញ្ញប្បទានមានទំនួលខុសត្រូវនិងបរិយាបន្នផ្នែកយេនឌ័រនាំ ឲ្យមានភាពខុសប្លែកគ្នានៅក្នុងរបៀបគ្រប់គ្រងធនធានទឹក។ អ្នកចូលរួមនឹងបានឃើញកិច្ចពិភាក្សាដ៏ទាក់ទាញ ការតាំងពិពណ៌បែបអន្តរកម្ម និងការចែករំលែកនូវបច្ចេកវិទ្យាទំនើបៗ និងដំណោះស្រាយប្រកបដោយប្រឌិតញាណ ដែលអាចចូលដោះស្រាយបញ្ហាប្រឈមនានារបស់ទន្លេមេគង្គអោយកាន់តែមានប្រសិទ្ធភាព។

សារសំខាន់ៗ និងអនុសាសន៍ដែលអាចអនុវត្តបានពីសន្និសីទ នឹងដាក់ទៅក្នុងកិច្ចប្រជុំកំពូលទីដែលថ្នាក់ដឹកនាំពីប្រទេសតាមដងទន្លេមេគង្គនឹងធ្វើការកំណត់ពីអនាគត និងទិសដៅជាយុទ្ធសាស្ត្រសម្រាប់ទន្លេមេគង្គ។

កិច្ចប្រជុំកំពូលនេះ គឺជាព្រឹត្តិការណ៍កម្រិតនយោបាយខ្ពស់បំផុតរបស់ MRC សំដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការទន្លេមេគង្គ ក្រោមក្របខណ្ឌ MRC តាមរយៈការពង្រឹងសាមគ្គីភាព និងការកំណត់ទិសដៅរួមក្នុងចំណោមប្រទេសតាមដងទន្លេមេគង្គនិងភាគីពាក់ព័ន្ធ។ កន្លងមក គេបានរៀបចំកិច្ចប្រជុំនេះចំនួនបីលើករួមមកហើយ÷ ក្នុងប្រទេសថៃ (២០១០) វៀតណាម (២០១៤) និងកម្ពុជា (២០១៨)។

សម្រាប់ព័ត៌មានបន្ថែមស្ដីពីកិច្ចប្រជុំកំពូលលើកទី៤និងសន្និសីទអន្តរជាតិរបស់ MRC នេះ សូមមើលគេហទំព័រ www.mrcsummit.org។

## កំណត់សម្គាល់សម្រាប់និពន្ធនាយក÷

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាលមួយដែលបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ដើម្បីលើកកម្ពស់និងជួយសម្របសម្រួលការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គប្រកបដោយចីរភាព។ ស្ថាប័ននេះបំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក និងជាមជ្ឈមណ្ឌលចំណេះដឹង ដោយអនុវត្តតាមកិច្ចព្រមព្រៀងទន្លេមេគង្គ ក្នុងចំណោមប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង÷

លោក ឡុង យូផេង | មន្ត្រីសារព័ត៌មាន
លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល÷ youpheng@mrcmekong.org
ទូរស័ព្ទដៃ÷ +៨៥៦-២០-៩៣-៤៤៤-១០៣

-ចប់-